# *FORMATION OF ADVERBS*

## (ការបង្កើត Adverb)

350. Adverbs of Manner are mostly formed from Adjectives by adding *ly* (a corruption of *like*); as,

350. Adverbs of Manner ភាគច្រើនគឺបង្កើតមកពី Adjective ថែម ly (ly មានន័យថាដោយរបៀប) ដូចជា

| | | |
|---|---|---|
| Clever | => | cleverly : យ៉ាងឈ្លាសវៃ (ដោយរបៀបឈ្លាសវៃ) |
| Wise | => | wisely : យ៉ាងឈ្លាសវៃ |
| Kind | => | kindly : ចិត្តល្អ/ ចិត្តរាក់ទាក់ |
| Foolish | => | foolishly : ដោយឆ្កួតៗ/ដោយភ្លី |
| Quick | => | quickly : យ៉ាងលឿន/ដោយលឿន |
| Beautiful | => | beautifully : យ៉ាងស្អាត |

Akbar was a *wise* king.

Akbar គឺជាស្តេចដ៏ឈ្លាសវៃ។

He ruled wisely for many years.

គាត់ដឹកនាំប្រទេសដោយឈ្លាសវៃអស់រយៈពេលជាច្រើនឆ្នាំ។

rule = ដឹកនាំប្រទេស/គ្រប់គ្រងប្រទេស

When the Adjective ends in *y* preceded by a consonant change *y* into *i* and add *ly*; as,

នៅពេលដែល Adj មានចុងបញ្ចប់ដោយ y នាំមុខដោយព្យញ្ជនៈចូរប្តូរ y នោះឲ្យទៅជា i បន្ទាប់មកថែម ly ដូចជា

| | | |
|---|---|---|
| Happy | => | happily |
| Ready | => | readily |
| Heavy | => | heavily |

When the Adjective ends in *le*, simply change *e* into *y*; as,

នៅពេលដែល Adj ចុងបញ្ចប់ដោយ le ចូរគ្រាន់តែប្តូរ e ឲ្យទៅជា y បានហើយ ដូចជា

| | | |
|---|---|---|
| Single (តែឯង/តែមួយ) | => | singly |
| Double | => | doubly |

351. Some Adverbs are made up of a Noun and a qualifying Adjective; as,

351. Adverb មួយចំនួនបង្កើតឡើងដោយ Noun និង Adjective បំពេញន័យឲ្យមួយ ដូចជា

Sometimes = ជួនកាល

*Meantime* / *Meanwhile* } = ទន្ទឹមពេលគ្នានេះដែរ

Yesterday,

Midway = ពាក់កណ្តាលផ្លូវ

Otherwise = បើមិនដូច្នោះទេ

352. Some Adverbs are compounds of *on* (weakened to a) and a Noun; as,

352. Adverb មួយចំនួនគឺជាពាក្យបូករវាង on (on: ធ្វើឲ្យចុះខ្សោយមកនៅត្រឹម a) ហើយបូកជាមួយ Noun ដូចជា

A-foot (on foot) = ដើរ, ថ្មើរជើង

abed (= in bed) = នៅលើគ្រែ

asleep = ដេកលក់

ahead = ខាងមុខ

aboard (= on board) = ដែលជិះនៅលើទូក (ទូក, នាវា , យន្តហោះ,....)

away = នៅឆ្ងាយ

Similarly there are other Adverbs which are also compounds of some Preposition and a Noun; as,

www.salarean.com

ដូចគ្នាអញ្ចឹងដែរមាន Adverb ដទៃៗទៀតជាច្រើនដែលជាពាក្យបូកផ្សំរវាង Preposition និង Noun ដូចជា

Bedtimes;

besides = ក្រៅពី;

today;

tomorrow;

overboard = ពីលើចំហៀងនាវា/លើគែមនាវា

[Note—The word *be* is an old form of the Preposition *by*.]

[ចូចំណាំ--ពាក្យ be នេះគឺជាទំរង់ចាស់ពីដើមរបស់ Preposition: by។]

353. Some Adverbs are compounds of a Preposition and an Adjective; as,

353. Adverb មួយចំនួនគឺជាពាក្យបូកផ្សំរវាង Preposition និង Adjective ដូចជា

Abroad = នៅឯបរទេស;

along;

alond = លឺៗ;

anew = ជាថ្មី;

behind;

below;

beyond;

354. Some Adverbs are compounds of a Preposition and an Adverb; as,

354. Adverb មួយចំនួនគឺជាពាក្យបូកផ្សំរវាង Prep និង Adv ដូចជា

Within = នៅខាងក្នុង;

without = នៅខាងក្រៅ;

before;

beneath = នៅខាងក្រោម.

355. There is a class of Adverbs which are derived from the Pronouns *the* (= that), he, who.

355. មាន Adverb មួយក្រុមដែលមានប្រភពចេញមកពី Pronoun: the (= that), he, who។

to be derive from = មានប្រភពចេញមកពី

| Pronouns | Adverb | | | | |
|---|---|---|---|---|---|
| | Place to | Motion from (ចលនាពី) | Motion (ចលនា) | Time (ពេលវេលា) | Manner (របៀប) |
| The | there | thither | thence | then | thus |
| He | here | hither | hence | ...... | ...... |
| Who | where | whither | whence | when | how |

thither (adv) = toward that place = ឆ្ពោះទៅទីនោះ

hither (adv) = toward this place = មកកាន់កន្លែងនេះ

wither (adv) = to what place = ទៅកន្លែងណា

thence (adv) = from there = ពីនោះ

hence (adv) = from here = ពីនេះ

whence (adv) = from where = ពីកន្លែងដែល

there in = in that

here-in = in this

www.salarean.com

thereby (adv) = by that means = តាមមធ្យោបាយឬរបៀបនេះ/ធ្វើដូច្នេះ

therefrom (adv) = from that/this = ពីនោះ

therein (adv) = in there; in that place = ក្នុងនោះ

thereof (adv) = of that; of it = នៃ (ឧ. ឯកសារ)នោះ

thereon (adv) = as a result of that = ជាលទ្ធផលនៃអ្វីនោះ

thereto (adv) = to that place = ទៅទីនោះ

therewith (adv) = $\left| \begin{matrix} along\ with\ that \\ in\ addition\ to\ that \end{matrix} \right|$ = ជាបន្ថែមលើនោះ

a copy thereof = ច្បាប់ចំលងនៃកិច្ចសន្យានោះមួយច្បាប់

a copy = ច្បាប់ចំលង

hereafter (adv) = from now on = ចាប់ពីពេលនេះតទៅ

hereby (adv) = by this means = តាមរយៈនេះ/តាមមធ្យោបាយនេះ

herein (adv) in this = ក្នុងនេះ

hereupon (adv) = upon this = ស្ដីពីបញ្ហានេះ/ទាក់ទងទៅនិងបញ្ហានេះ

herewith (adv) = with this = ជាមួយនេះ (ឧ. ជាមួយលិខិតនេះ)

Please fill in the form enclosed *herewith*.

សូមបំពេញបែបបទដែលមានភ្ជាប់មកជាមួយលិខិតនេះ។

wherefore (adv) = for what reason or purpose?

= តើដោយសារមូលហេតុអ្វី?

= តើដើម្បីគោលបំណងអ្វី?

My $\underbrace{\underbrace{journey}_{N} \underbrace{\ }_{+} \underbrace{hither}_{Adv}}_{NP}$ = ការធ្វើដំណើររបស់ខ្ញុំមកកាន់ទីកន្លែងនេះ

...... The Traitor′s Gate, whither $\underbrace{so\ many}_{Subject}$ $\underbrace{came}_{Verb}$ to their death,......

...... កន្លែង Traitor′s Gate ដែលមនុស្សជាច្រើនបានមករកសេចក្ដីស្លាប់នៅទីនេះ........

to come to one′s death = មករកសេចក្ដីស្លាប់

whither (adv) = ដែលទៅកាន់កន្លែងណាមួយនោះ

I enclose some photograph of me.

ខ្ញុំភ្ជាប់មកជាមួយ(សំបុត្រ)នូវរូបថតខ្ញុំ។

to find $\underbrace{sth}_{obj}$ $\underbrace{enclosed}_{(C)of\ Obj}$ = ភ្ជាប់មកជាមួយនូវអ្វី១

Enclosed, you will find sth.

= (ភ្ជាប់មកជាមួយអ្នកនឹងឃើញមានsth)

= ខ្ញុំបានភ្ជាប់មកជាមួយនូវ sth

= ភ្ជាប់មកជាមួយ(សំបុត្រនេះ) អ្នកនឹងឃើញមាន sth

$\underbrace{Enclosed}_{C}$ herewith, you will find sth

ខ្ញុំបានភ្ជាប់មកជាមួយសំបុត្រនេះនូវអ្វី១

Fill in the form $\underbrace{enclosed\ herewith}_{Adj\ Clause}$.

Fill in the form (~~which is~~) enclosed herewith.

ចូរបំពេញបែបបទដែលមានភ្ជាប់មកជាមួយលិខិតនេះ។

www.salarean.com

All persons born or naturalized in the United States and *subject* (Adj) to the jurisdiction thereof, are citizens of the US.

បុគ្គលទាំងអស់ដែលកើតឬចូលសញ្ជាតិនៅក្នុងសហរដ្ឋអាមេរិក ហើយស្ថិតនៅក្រោមយុត្តាធិការរបស់សហរដ្ឋអាមេរិក គឺជាពលរដ្ឋរបស់សហរដ្ឋអាមេរិក។

*subject* (Adj) to sth = អាស្រ័យលើ / ស្ថិតនៅក្រោម

jurisdiction (n) = យុត្តាធិកា (ដែនសមត្ថកិច្ច)

He charged $20 for each session, or any part *thereof* (= *of the session.*).

គាត់ទារថ្លៃ២០ដុល្លារសំរាប់មួយ Session ឬក៏ផ្នែកណាមួយនៃមេរៀនមួយនោះ។

to charge = ទារថ្លៃ

Session = ការបង្រៀនម្តង១ម៉ោងឬ២ម៉ោង គេហៅថា១ Session។

therein (adv) = in that = នៅក្នុងនោះ / នៅក្នុងអាហ្នឹង

...... the lake and the fish *therein* (ជំនួសឲ្យ the lake) (= *in the lake*).

...... បឹងហើយនិងត្រី នៅក្នុងអាហ្នឹង

...... បឹងហើយនិងត្រី នៅក្នុងបឹងនោះ

...... the world and all that *therein* (=*in the world*) dwelt.

...... ពិភពលោកនិងអ្វីទាំងអស់ដែលរស់នៅក្នុងពិភពលោកនោះ។

to dwelt = រស់នៅ

...... Sok (hereafter referred to as "Party A")......

......សុក្រ (ដែលចាប់ពីពេលនេះតទៅមានឈ្មោះថាភាគី«ក»......

OR *hereinafter* referred to as......

ចាប់ពីពេលនេះតទៅក្នុងកិច្ចសន្យានេះមានឈ្មោះហៅថា......

Whence (adv) = from where = ពីកន្លែងដែល

They have returned *whence* they came.

ពួកគេបានវិលត្រឡប់មកវិញពីកន្លែងណាដែលពួកគេបានមក។

ពួកគេមកពីកន្លែងណាបានទៅកន្លែងហ្នឹងវិញហើយ។

ពួកគេវិលត្រឡប់ទៅទីកាន់ទីកន្លែងដែលពួកគេមក។

Hence (adv) = from here = ពីទីនេះទៅ

We arrive at the side gate. *Hence* steps lead down to a garden.

យើងបានទៅដល់ក្លោងទ្វារចំហៀង។ ពីទីនេះទៅកាំជណ្តើរចុះសំដៅទៅរកសួនច្បារមួយ។

gate = ក្លោងទ្វារ

side gate = ក្លោងទ្វារចំហៀង

Wherefore (adv) = for what reason or purpose? តើដោយសារមូលហេតុអ្វី? ឬ តើក្នុងគោលបំណងអ្វី?

Wherein = in which = ដែលនៅក្នុងនោះ

Whereon = after which; and then = បន្ទាប់ពីនោះមក

Whereof = of what, which, or whom = ដែលអំពីអ្វី១ឬអ្នកនោះ

www.salarean.com

The things *whereof* he spoke……

រឿងរ៉ាវដែលគាត់បាននិយាយ (*អំពីរឿងរ៉ាវនោះ*)

(The things of which he spoke……)

Hitherto = until now = រហូតមកដល់ពេលនេះ

e.g. A men reformed to hitherto as Mrs X…

ស្ត្រីម្នាក់ដែលរហូតមកដល់ពេលនេះ គេហៅឈ្មោះថា Mrs X…

thenceforth/thenceforward = from that time on-ward = ចាប់ពីពេលនោះតទៅ

henceforth/henceforward = from this time on = ចាប់ពីពេលនេះតទៅ

357. Two Adverbs sometimes go together, joined by the Conjunction *and*; as,

357. Adverb ពីរជួនកាលនៅជាមួយគ្នា ភ្ជាប់ដោយ Conjunction *and* ដូចជា

go together = ឈរនៅជាមួយគ្នា/មានទីតាំងនៅជាមួយគ្នា

again and again (= more than once, repeatedly),

ម្តងហើយម្តងទៀត/ដដែលជាដដែល (= ច្រើនដង/ញយដង, ដដែលៗ)

by and by (= before long, presently, after a time),

ក្នុងពេលឆាប់ៗ (= ក្នុងពេលឆាប់ៗ/ក្នុងពេលមិនយូរ, បច្ចុប្បន្ន, បន្ទាប់ពីអស់ពេលមួយរយៈមក)

far and near (= in all directions)

គ្រប់ទិសទី/ជិតឆ្ងាយ/គ្រប់ច្រកល្ហក

far and wide (= comprehensively),

(1) គ្រប់ទិសទី

(2) យ៉ាងទូលំទូលាយ

far and away (= by a great deal, decidedly, beyond all comparison),

យ៉ាងខ្លាំង, ជាខ្លាំង, មែនទែន, ក្រៃលែង (= ច្រើន/ខ្លាំង, យ៉ាងច្បាស់, វាហួសពីការប្រៀបធៀប),

far and away ប្រើជាមួយ Comparison គឺ Comparative និង Superlative សង្កត់ន័យ)

far and away + Comparative/Superlative = យ៉ាងខ្លាំង/ជាខ្លាំង

first and foremost (= first of all [=ជាបឋម]),

now and then (= from time to time, occasionally),

ម្តងម្កាល/ជារឿយៗ

now and again (= at intervals, sometimes, occasionally),

ម្តងម្កាល/ជារឿយៗ

off and on (= not regularly, intermittently),

ម្តងម្កាល

once and again (= on more than one occasion, repeatedly),

ជាច្រើនដង/ជាញយដង

out and away (= beyond comparison, by far),

យ៉ាងខ្លាំង/ក្រៃលែង (ប្រើជាមួយ Comparative)

out and out (= decidedly, beyond all comparison),

ទាំងស្រុង/យ៉ាងខ្លាំង/ក្រៃលែង

over and above (= in addition to, besides, as well as),

ក្រៅពី

over and over (= many times, frequently, repeatedly),

ច្រើនដង/ម្តងហើយម្តងទៀត

www.salarean.com

through and through (= through, completely),
ទាំងស្រុង
thus and thus (= in such and such a way),
របៀបនេះ/ដោយរបៀបនេះ
to and fro (= backwards and forwards, up and down),
ទៅមកៗ
Goods books should be read *again and again*.
សៀវភៅល្អគួរតែអានម្តងហើយម្តងទៀត។
I warned him *again and again*.
ខ្ញុំបានព្រមានគាត់ម្តងហើយម្តងទៀត។
*By and by* the turmult will subside.
មិនយូរប៉ុន្មាន ភាពច្របូកច្របល់នឹងស្ងប់ស្ងាត់។

turmult (n) = ភាពច្របូកច្របល់/ភាពវឹកវរ

subside = (ទឹក) ស្រក, (ភាពចលាចល) ស្ងប់ស្ងាត់

His fame has spread *far and near*.
កេរ្តិ៍ឈ្មោះរបស់គាត់លឺសុះសាយគ្រប់ទិសទី។

far and near = (1) (សាច់ញាតិ) សាច់ជិតឆ្ងាយ , (2) គ្រប់ទិសទី

fame = កេរ្តិ៍ឈ្មោះ

spread = លឺសុះសាយ

As a statesmen he saw *far and wide*.
ក្នុងនាមជារដ្ឋបុរស គាត់មើលឃើញបានទូលំទូលាយ។

statesmen (n) = រដ្ឋបុរស

As = ក្នុងនាមជា / ក្នុងឋានៈជា

This is *far and away* (ប្រើសង្កត់ន័យឲ្យ Superlative) *the best* (superlative) course.
នេះគឺជាផ្លូវដ៏ល្អប្រសើរបំផុត/យ៉ាងក្រៃលែង។
He is *far and away the best* bowler in our eleven.
គាត់ជាអ្នកបោះប៊ូលដ៏ល្អជាងគេបង្អស់នៅក្នុងក្រុម១១នាក់របស់យើង។
He now and then writes on fiscal questions.
ជារឿយៗ/ម្តងម្កាល គាត់សរសេរពីបញ្ហាសារពើពន្ធ។

fiscal question = បញ្ហាសារពើពន្ធ

fiscal (adj) = សារពើពន្ធ

e.g. | *fiscal* / *financial* | year = ឆ្នាំសារពើពន្ធ

I write to him *now and then*.
ខ្ញុំសរសេរសំបុត្រទៅលេងគាត់/ទៅសួរសុខទុក្ខគាត់ម្តងម្កាល។
He worked ten years, off and on, on his Pali.
ម្តងម្កាល គាត់បានធ្វើកិច្ចការអស់រយៈពេល១០ឆ្នាំលើវចនានុក្រមបាលីរបស់គាត់។

to work on = គិតធ្វើកិច្ចការលើ

Pali = បាលី

I have told you *once and again* that you must not read such trash.
ខ្ញុំបានប្រាប់អ្នកឯងញយដងហើយថាអ្នកឯងមិនត្រូវអានរបស់ដែលគ្មានតំលៃបែបហ្នឹងនោះទេ។

www.salarean.com

trash = (1) សំរាម; (2) (អត្ថបទ) សៀវភៅឬអត្ថបទដែលគ្មានតំលៃ

This is *out and away the best* work on Astronomy.

នេះគឺជាស្នាដៃដ៏ល្អប្រសើរបំផុតស្ដីអំពីតារាសាស្ត្រ។

Astronomy = តារាសាស្ត្រ/តារាវិទ្យា

work = ស្នាដៃ

He gained *over and above* this, the goodwill of all people.

OR: Over and above this, he gained the goodwill of all people.

{ ក្រៅពីនេះគាត់ទទួលបាននូវ / គាត់ទទួលបានក្រៅពីនេះមាន } សុឆន្ទរបស់ប្រជាជនទាំងអស់។

to gain = ទទួលបាន

over and above this = ក្រៅពីនេះ

over and above = ក្រៅពី

*Over and above being* (G) hard-working he is thoroughly honest.

ក្រៅពីខំធ្វើការ គាត់ស្មោះត្រង់ទាំងស្រុង/មែនទែន។

to work hard = ខំធ្វើការ

hard-working (adj) = ដែលខំធ្វើការ/ដែលខំរៀន

thoroughly = ទាំងស្រុង

honest (n) = ស្មោះត្រង់

He reads all the novels of Scott *over and over*.

គាត់អានរឿងប្រលោមលោកទាំងអស់របស់ Scott ម្ដងហើយម្ដងទៀត។

I believe Sachin is *out and out the best* India batsman.

ខ្ញុំជឿថា Sachin គឺជាអ្នកវាយបាល់ដ៏ល្អជាងគេបង្អស់របស់ឥណ្ឌា។

He has read Milton *through and through*.

គាត់អានអត្ថបទរបស់ Milton ម្ដងហើយម្ដងទៀត។

to read sth through = អាន sth ពីដើមដល់ចប់

to read sth through and through = អានហើយអានទៀត/អានមួយចប់ហើយមួយចប់ទៀត

*Thus and thus* only we shall succeed.

{ ដោយរបៀបហ្នឹង / ធ្វើអញ្ចឹង } មានតែយើងទេ { នឹង / ទើប } ទទួលបរាជ័យ។

He walked *to and fro*, meditating.

គាត់ដើរចុះដើរឡើងដោយភាវនា។

meditating = តាំងសមាធិ, ភាវនា

to meditate

www.salarean.com